ចៅហ្វាយ៣:១២-៤:២៤

## ពួកចៅហ្វាយទី២ : លោកអេហ៊ុឌ

**លុះក្រោយមក ពួកកូនចៅអ៊ីស្រាអែល ក៏ប្រព្រឹត្តសេចក្ដីដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាទៀត រួចព្រះយេហូវ៉ាទ្រង់បានចំរើនកំឡាំងដល់អេក្លុន ជាស្តេចស្រុកម៉ូអាប់ឲ្យទាស់នឹងអ៊ីស្រាអែល ពីព្រោះគេបានប្រព្រឹត្តសេចក្ដីដ៏លាមកអាក្រក់នៅព្រះនេត្រទ្រង់ (ចៅហ្វាយ៣:១២)។**

កាំកង់ប្រវត្តិសាស្រ្តរបស់សាសន៍អ៊ីស្រាអែល វិលដូចពីមុនទៀតហើយ។ សាសន៍អ៊ីស្រាអែលនាំគ្នាបម្រើព្រះបានមួយរយៈ រួចហើយក៏នាំគ្នាបែរខ្នងដាក់ព្រះជាម្ចាស់ ដោយធ្វើការអាក្រក់លាមកនៅចំពោះព្រះនេត្រទ្រង់។

លោកអេហ៊ុឌ ជាពួកចៅហ្វាយមួយរូបដែលព្រះជាម្ចាស់តាំងឡើង ដើម្បីរំដោះសាសន៍អ៊ីស្រាអែល។ លោកមានស្នាដៃតិចណាស់ បើយើងសង្កេតអោយបានល្អិតល្អន់។ លោកមិនបានធ្វើអ្វីក្រៅអំពីសម្លាប់ស្តេចមួយអង្គឈ្មោះអេក្លុនតែប៉ុណ្ណោះ។ លោកមានលក្ខណៈដោយឡែកម្យ៉ាង គឺលោកជាមនុស្សចេះប្រើដៃឆ្វេង។ លោកប្រើដៃឆ្វេងរបស់លោក ដើម្បីរំដោះសាសន៍អ៊ីស្រាអែលអោយរួចអំពីការជិះជាន់របស់

សាសន៍ដទៃ។ លោកអេហ៊ុឌ ពិតជាមនុស្សមួយរូបដែលព្រះជាម្ចាស់ប្រើដើម្បីសម្រេចកិច្ចការនេះ។ លោកធ្វើគុតស្តេចមួយអង្គនាមអេក្លុន ដើម្បីរំដោះសាសន៍របស់លោកអោយរួចអំពីភាពខ្ញុំគេ។ ពេលខ្លះព្រះជាម្ចាស់បណ្តោយអោយជម្ងឺមហារីកវាតត្បាតដល់បុគ្គលណាម្នាក់ ដើម្បីជួយសង្គ្រោះព្រលឹងរបស់ជននោះ។ ដោយសារអេហ៊ុឌហ៊ានសម្រេចក្តីជាមួយនឹងស្តេចអេក្លុន បានជាមនុស្សរាប់ពាន់រាប់លាននាក់ អាចរួចអំពីការជិះជាន់យ៉ាងព្រៃផ្សៃ។

ខ្ញុំចង់ជម្រាបដល់លោកអ្នកបងប្អូនបន្តិច អំពីដំណើរដែលព្រះជាម្ចាស់ទ្រង់ប្រើអេហ៊ុឌ ដើម្បីរំដោះសាសន៍អ៊ីស្រាអែលអោយរួចអំពីខ្ញុំគេ។ លោកអេហ៊ុឌមិនមានសមត្ថភាពអ្វីធំដុំក្រៅពីលោកចេះប្រើដៃឆ្វេងតែប៉ុណ្ណោះទេ។ ទោះបីលោកមិនមានសមត្ថភាពអ្វីល្អប្រសើរជាងនេះ ក៏ព្រះជាម្ចាស់អាចប្រើលោកកើតដែរ។ នៅក្នុងសម័យបច្ចុប្បន្ននេះ ព្រះជាម្ចាស់កំពុងប្រើមនុស្សដែលព្រមធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។ លោករៀលីយ៉ាំខ័វរី ជាគ្រីស្ទបរិស័ទជនជាតិអង់គ្លេសមួយរូប មានកិរិយាទន់ភ្លន់ព្រមទាំងជាអ្នកបន្ទាបខ្លួនពេកក្រៃ។ លោកជាបិតានៃចលនាបេសកកម្ម របស់គ្រីស្ទបរិស័ទក្នុងសម័យបច្ចុប្បន្ន។ ម្យ៉ាងទៀត លោកដ្វៃត៍មូឌី ដែលរៀនសូត្របានតិចតួចណាស់ តែលោកជាអ្នកដែលបង្កើតចលនាសិក្សាអប់រំយ៉ាងខ្លាំង នៅក្នុងចំណោមពួកគ្រីស្ទបរិស័ទ។ មួយវិញទៀត លោកខែបបល់មរហ្គិន ជាគ្រូអធិប្បាយព្រះបន្ទូលព្រះអង្គដ៏ចំណាន ថ្វីដ្បិតពាក្យសម្តីរបស់លោកនិយាយមិនសូវជាហួរហែរយ៉ាងណាក៏ដោយ។ លោកទាំង៣ជាទូតរបស់ព្រះជាម្ចាស់ ដែលទ្រង់ប្រើសម្រាប់សម្រេចកិច្ចការរបស់

ទ្រង់។

មានបុរសម្នាក់ទៀត ដែលព្រះជាម្ចាស់ប្រើយ៉ាងខ្លាំងអស្ចារ្យណាស់ដែរ។ លោកនោះនាមហ្គេស៊ីធិននី ដែលជាកូនគ្រូអធិប្បាយមួយរូប។ នៅពេលឪពុករបស់លោកស្លាប់ទៅ ម្តាយលោករស់នៅដោយក្រខ្សត់ជាទីបំផុត ពីព្រោះក្រុមជំនុំមិនបានរៀបចំកម្រៃអ្វីសម្រាប់ជួយដល់ភរិយាមេម៉ាយរបស់គ្រូគង្វាលទេ។ លោកហ្គេស៊ីធិននីដាក់កិច្ចសន្យានៅចំពោះព្រះថា បើលោកអាចរកស៊ីធ្វើជាអ្នកមាន លោកនឹងជួយដល់ភរិយាគ្រូគង្វាលទាំងអស់ ដែលប្តីស្លាប់ទៅ ហើយមិនមាននរណាជួយឡើយ។ សព្វថ្ងៃមានគេហដ្ឋានមួយឈុត ដែលលោកសង់ឡើងសម្រាប់ទទួលគ្រូគង្វាលដែលចូលនិវត្តន៍ និងស្ត្រីមេម៉ាយ ជាភរិយារបស់គ្រូគង្វាល ដែលប្តីស្លាប់ចោល។ ព្រះជាម្ចាស់បានប្រើលោកដោយប្រថុយនោះ។ ព្រះជាម្ចាស់អាចប្រើដល់មនុស្សសាមញ្ញ ដើម្បីអោយសម្រេចការជាច្រើន នៅក្នុងរាជ្យរបស់ទ្រង់ បើជនទាំងនោះស្ម័គ្រចិត្តអនុញ្ញាតអោយព្រះអង្គប្រើដោយស្ម័គ្រពីចិត្ត។

**ស្តេចនោះក៏ប្រមូលពួកកូនចៅអាំម៉ូន នឹងពួកអាម៉ាលេកមក រួចចូលទៅវាយពួកអ៊ីស្រាអែល ហើយចាប់យកបានទីក្រុងដើមលម៉ើរបស់គេ (ចៅហ្វាយ៣:១៣)។**

ក្នុងគ្រាដែលសាសន៍អ៊ីស្រាអែលធ្វើខុសនឹងបំណងព្រះហឫទ័យរបស់ព្រះ ព្រះអង្គបណ្តោយអោយសាសន៍នេះធ្លាក់ទៅជាខ្ញុំគេ។ តើមានអ្វីកើតឡើងបន្ទាប់មកទៀត?

**[១៤] ពួកកូនចៅអ៊ីស្រាអែលក៏នៅជាចំណុះអេគ្លុន ជាស្តេចសាសន៍ម៉ូអាប់នោះអស់១៨ឆ្នាំ [១៥] តែកាលគេបានអំពាវនាវដល់ព្រះយេហូវ៉ា នោះទ្រង់តាំងឲ្យមានអ្នក១ ជាអ្នកជួយសង្គ្រោះដល់គេ គឺអេហ៊ុឌ ជាកូនកេរ៉ាក្នុងពូជអំបូរបេនយ៉ាមីន ដែលជាអ្នកប្រើការខាងដៃឆ្វេង ពួកកូនចៅអ៊ីស្រាអែលបានផ្ញើសួយអាករទៅថ្វាយអេគ្លុន ជាស្តេចសាសន៍ម៉ូអាប់នោះ ដោយសារលោក (ចៅហ្វាយ ៣:១៤-១៥)។**

ក្រោយមកយើងឃើញថា កាំកង់ប្រវត្តិសាស្ត្ររបស់សាសន៍អ៊ីស្រាអែលវិញដូចមុនទៀតហើយ។ សាសន៍អ៊ីស្រាអែលស្រែកអំពាវនាវដល់ព្រះជាម្ចាស់ រួចហើយព្រះអង្គតាំងចៅហ្វាយម្នាក់អោយរំដោះគេចេញអំពីទុក្ខលំបាកនោះ។ ចៅហ្វាយរូបនោះនាមលោកអេហ៊ុឌ ត្រូវជាកូនរបស់កេរ៉ាក្នុងត្រកូលបេនយ៉ាមីន ជាអ្នកដែលចេះប្រើដៃឆ្វេងយ៉ាងស្ទាត់ជំនាញ។ ដំណើរនេះជាការលើកទឹកចិត្តដល់យើងទាំងអស់គ្នាណាស់។ មនុស្សម្នាក់ដែលចេះប្រើដៃឆ្វេងយ៉ាងស្ទាត់ជំនាញ អាចត្រឡប់មកជាអ្នកបំរើរបស់ព្រះយ៉ាងចំណាប់ម្នាក់ដែរ។

១៦ឯអេហ៊ុឌ លោកធ្វើកាំបិត១ មានមុខពីរ ប្រវែង១ហត្ថសំរាប់
ខ្លួន ហើយសៀតភ្ជាប់នៅចង្កេះខាងស្តាំត្រង់ក្រោមអាវ ១៧លោក
ក៏ចូលទៅថ្វាយសួយអាករដល់អេក្លូន ជាស្តេចសាសន៍ម៉ូអាប់ (រីឯ
អេក្លូន នោះជាមនុស្សធាត់ខ្លាំងណាស់) ១៨កាលបានថ្វាយសួយ
អាករជាស្រេច នោះក៏នាំគ្នាទៅដល់ត្រឹមកន្លែងដាប់ថ្ម ដែលនៅ
ជិតគីលកាល ១៩រួចលោកឱ្យពួកអ្នកដែលកាន់នាំសួយអាករមក
ត្រឡប់ទៅស្រុកវិញ តែឯខ្លួនលោកៗវិលចូលមកឯស្តេចទូលថា
បពិត្រព្រះករុណា ទូលបង្គំមានការយ៉ាងសំងាត់នឹងទូលដល់ទ្រង់
ដូច្នេះស្តេចទ្រង់ក៏បង្គាប់ថា ចូរស្ងៀមសិន រួចអស់អ្នកដែលឈរ
ជិតក៏នាំគ្នាចេញទៅក្រៅអស់ទៅ ២០ឯស្តេចទ្រង់គង់នៅតែឯង
ក្នុងបន្ទប់ខាងលើ ជាកន្លែងសំរាប់លំហើយអង្គ លំដាប់នោះ
អេហ៊ុឌក៏ចូលទៅជិតទ្រង់ទូលថា ទូលបង្គំមានព្រះបន្ទូលនៃព្រះ
សំរាប់នឹងទូលដល់ទ្រង់ ស្តេចក៏ក្រោកចាកពីព្រះទែនឡើង
២១នោះអេហ៊ុឌក៏លូកដៃឆ្វេងទៅ ដកយកកាំបិតពីចង្កេះខាងស្តាំ
ចាក់ត្រង់ពោះនៃស្តេច ២២ឯដងកាំបិតក៏មុតកប់ចូលទៅតាមផ្លែផ្ទុះ
ចេញទៅខាងក្រោយ រួចខ្លាញ់បិទភ្ជិតទាំងអស់ទៅ លោកឥតបាន
ដកកាំបិតចេញពីពោះស្តេចឡើយ ២៣ស្រេចហើយក៏ចេញមក
ឯរានខាងមុខ រួចបិទទ្វារបន្ទប់ខាងលើនោះចាក់សោភ្ជិតទៅ

**(ចៅហ្វាយ៣:១៦-២៣)។**

ឯដំណើរដែលលោកអេហ៊ុឌបានសម្រេចទិសដៅរបស់ខ្លួន ក្នុងការរំដោះសាសន៍អ៊ីស្រាអែល គឺលោកធ្វើកាំបិតមួយមានមុខពីរប្រវែងជាមួយ១ហត្ថ។ គាត់យកកាំបិតនោះសៀតភ្ជាប់នៅចង្កេះខាងស្ដាំគ្របអាវជិត។ ដោយសារនៅសម័យនោះមនុស្សខ្លាំងពូកែ ច្រើនតែជាអ្នកប្រើដៃស្ដាំ បានជាគេតែងតែឆែកមើលតែខាងឆ្វេងពីព្រោះជាកន្លែងដែលគេលាក់អាវុធ។ ចំណែកលោកអេហ៊ុឌយកអាវុធរបស់លោកលាក់នៅខាងស្ដាំវិញ។ អង្គរក្សរបស់ស្ដេចអេក្លូនឆែកលោកអេហ៊ុឌខុសកន្លែង។ លោកអាចចូលទៅគាល់ស្ដេចអេក្លូនបាន ដោយមានអាវុធចូលយកទៅជាមួយផង។ ស្ដេចអេក្លូនធាត់ហើយមានខ្លាញ់ច្រើនណាស់។ បន្ទាប់ពីអេហ៊ុឌបានយកសួយសាអាករទៅថ្វាយដល់ស្ដេចអង្គនោះ លោកធ្វើពើហាក់ដូចជាចង់ទូលថ្វាយស្ដេចអង្គនោះពីរឿងអ្វីមួយដោយសម្ងាត់។ ស្ដេចអេក្លូនក៏បញ្ជាអោយអង្គរក្ស និងអ្នកមុខអ្នកការចេញបាត់ទៅ។ បន្ទាប់ពីមនុស្សម្នាចេញអស់ហើយ លោកអេហ៊ុឌក៏ដកកាំបិតស្នៀតចាក់ចូលទៅក្នុងពោះរបស់ស្ដេចអេក្លូន។ កាំបិតស្នៀតកប់នៅក្នុងខ្លាញ់ពោះរបស់ស្ដេចអេក្លូនរួចហើយអេហ៊ុឌចាក់សោទ្វារចេញបាត់ទៅ។

លោកអេហ៊ុឌមិនមែនជាមនុស្សកំសាកទេ ពីព្រោះលោកឆ្លៀតពេលកំពុងដែលពួកអង្គរក្សមិនទាន់អើពើ លោកក៏ចេញក្នុងពេលនោះតែម្ដង។

**២៤ កាលលោកបានចេញទៅបាត់ហើយ នោះពួកគាល់ហ្វៀរបស់**
**ស្ដេចមកឃើញទ្វារចាក់សោជិតដូច្នោះ ក៏គិតថា ប្រាកដជាទ្រង់ផ្ទំ**
**នៅក្នុងបន្ទប់នោះហើយ ២៥ រួចគេនៅចាំទាល់តែមានសេចក្ដីអៀន**
**ខ្មាសដល់ខ្លួន តែទ្រង់មិនបានបើកទ្វារបន្ទប់នោះសោះ គេក៏យក**
**កូនសោទៅចាក់បើកទ្វារ នោះឃើញម្ចាស់របស់គេ ទ្រង់សុគត**
**នៅលើឥដ្ឋហើយ (ចៅហ្វាយ៣:២៤-២៥)។**

ពួកបាវបម្រើទាំងអម្បាលមាណរបស់ស្ដេចអេគ្លូន ដែលត្រូវជាស្ដេចរបស់សាសន៍ម៉ូអាប់នាំគ្នារង់ចាំនៅខាងក្រៅអស់ជាយូរ។ ដោយសារឃើញទ្វារចាក់សោ គេស្មានថា ស្ដេចទ្រង់ផ្ទំនៅឡើយ។ ធម្មតាបាវបម្រើរបស់ស្ដេចមិនដែលហ៊ានតើនស្ដេចក្នុងពេលដែលស្ដេចផ្ទំទេ។ គេនាំគ្នារង់ចាំរហូតដល់គេមានសេចក្ដីខ្មាសអៀន។ លុះគេនាំគ្នាបើកទ្វារ គេឃើញថា ស្ដេចអេគ្លូនបានចូលទីវង្គត់បាត់ទៅហើយ។

**ឯអេហ៊ុឌ លោកបានរត់រួចទៅ កំពុងដែលអ្នកទាំងនោះនៅរារង់បង្អង់ចាំ ក៏បានទៅហួសពីកន្លែងដាប់ថ្មនោះ ចូលទៅដល់សៃរ៉ា (ចៅហ្វាយ៣:២៦)។**

នៅពេលដែលពួកបាវបម្រើរង់ចាំស្ដេច លោកអេហ៊ុឌក៏ឆក់ឱកាសនោះដើម្បី

គេចខ្លួន។ លោកបានចេញពីទឹកដីរបស់សាសន៍ម៉ូអាប់ទៅដល់កន្លែងមួយទៀតឈ្មោះសៃរ៉ា។ ពួកសាសន៍ម៉ូអាប់មិនអាចតាមរកលោកអេហ៊ុឌឃើញឡើយ។

> **[២៧]លុះដល់ហើយ នោះលោកផ្លុំត្រែឡើងនៅក្នុងស្រុកភ្នំអេប្រាអិម**
> **ឯពួកកូនចៅអីស្រាអែលក៏ចុះពីស្រុកភ្នំទៅជាមួយ មានលោកជា**
> **អ្នកនាំមុខគេ [២៨]លោកបង្គាប់ថា ចូរមកតាមខ្ញុំចុះ ដ្បិតព្រះយេ**
> **ហូវ៉ាទ្រង់បានប្រគល់ពួកសាសន៍ម៉ូអាប់ជាខ្មាំងសត្រូវ មកក្នុង**
> **កណ្តាប់ដៃអ្នករាល់គ្នាហើយ ដូច្នេះគេក៏ចុះតាមលោកទៅ ចាប់**
> **យកទីឆ្លងទន្លេយ័រដាន់ពីសាសន៍ម៉ូអាប់ ឥតបើកឱ្យអ្នកណាមួយ**
> **ឆ្លងសោះឡើយ [២៩]នៅវេលានោះគេប្រហារជីវិតសាសន៍ម៉ូអាប់**
> **អស់ប្រហែលជា១ម៉ឺននាក់ សុទ្ធតែជាមនុស្សក្លាហានហើយស្ទាត់**
> **ជំនាញគ្រប់គ្នា គ្មានអ្នកណាមួយរួចឡើយ [៣០]ដូច្នេះសាសន៍ម៉ូអាប់**
> **ត្រូវក្រាបចុះនៅក្រោមចំណាច នៃពួកអីស្រាអែល នៅថ្ងៃនោះ**
> **ឯងវិញ នោះស្រុកក៏បានសុខសាន្តប្រាណអស់៨០ឆ្នាំ (ចៅហ្វាយ**
> **៣:២៧-៣០)។**

## ពួកចៅហ្វាយទី៣ : លោកសាំកើរ

នៅក្នុងសម័យពួកចៅហ្វាយ ព្រះជាម្ចាស់តែងតែត្រាស់ហៅមនុស្សសាមញ្ញធម្មតា ដើម្បីមកប្រើប្រាស់អោយសម្រេចទិសដៅដ៏ធំរបស់ទ្រង់។ បើព្រះអង្គអាចប្រើមនុស្សធម្មតានៅសម័យដើមបាន ព្រះអង្គនៅតែបន្តប្រើប្រាស់មនុស្សធម្មតាដូចរូបលោកអ្នកនិងរូបខ្ញុំផ្ទាល់ផងដែរ។ ឥឡូវនេះសូមយើងពិចារណាបន្តិចអំពីបុគ្គលិកលក្ខណៈរបស់ពួកចៅហ្វាយទី៣ ដែលមាននាមថា លោកសាំកើរ។

**ក្រោយពីលោកមក មានឈ្មោះសាំកើរ ជាកូនអ័ណាត ដែលយកជន្លួញគោ វាយសំឡាប់ពួកភីលីស្ទីនអស់៦០០នាក់ អ្នកនោះក៏ជួយសង្គ្រោះអ៊ីស្រាអែលដែរ (ចៅហ្វាយ៣:៣១)។**

នៅក្នុងករណីដែលព្រះជាម្ចាស់ប្រើលោកសាំកើរ ព្រះអង្គមិនមែនប្រើតែមនុស្សទេ ប៉ុន្តែព្រះអង្គប្រើរបៀបដែលមនុស្សនោះអាចបម្រើព្រះអង្គបាន។ លោកសាំកើរមិនមានបុគ្គលិកលក្ខណៈណា ដែលគួរអោយព្រះជាម្ចាស់យកមកប្រើទេ។ លោកសាំកើរមានតែជន្លួញគោតែម្យ៉ាងប៉ុណ្ណោះ។ ជន្លួញគោមិនមានលក្ខណៈណាដែលអាចយកមកធ្វើចម្បាំងបានឡើយ។ ប៉ុន្តែសម័យនោះសាសន៍អ៊ីស្រាអែលមិនមានគ្រឿង

ដែកណាដែលអាចមកធ្វើជាសស្ត្រាវុធរបស់ខ្លួនឡើយ។ លោកមានតែជន្លួញគោ១ ប៉ុណ្ណោះសម្រាប់ប្រើប្រាស់។

សូមយើងពិចារណាបន្តិចអំពីវិធីដែលព្រះជាម្ចាស់ប្រើ។ វិធីដែលព្រះជាម្ចាស់ប្រើជន្លួញគោ មានលក្ខណៈល្អប្រសើរ។ យើងគិតថា កាលណាមានលក្ខណៈល្អប្រសើរហើយ ប្រហែលជាដំណឹងល្អបានកើនច្រើនជាងពីមុនហើយមើលទៅ។ ប៉ុន្តែលោកអ្នកបងប្អូនអើយ ព្រះជាម្ចាស់មិនមែនយកព្រះទ័យទុកដាក់ខ្លាំងពេកនៅលើវិធីទេ គឺព្រះអង្គយកព្រះទ័យទុកដាក់លើព្រះបន្ទូលព្រះអង្គ ដែលចេញទៅដោយមានប្រសិទ្ធភាព។ សម័យបច្ចុប្បន្នបេសកជនធ្វើដំណើរដោយប្រើយន្តហោះ ប្រើរទេះភ្លើង ព្រមទាំងប្រើយាន្តជំនិះទំនើបគ្រប់បែបយ៉ាង ដើម្បីបញ្ជូនបេសកជនទៅដល់ទីកន្លែងដែលត្រូវបម្រើព្រះអង្គ។ សព្វថ្ងៃមានវិទ្យុ មានទូរទស្សន៍សម្រាប់បម្រើព្រះអង្គដែរ។ ប៉ុន្តែមធ្យោបាយទាំងនោះ មិនមែនប្រសើរណាស់ណាទេ បើមិនយកមកប្រើដើម្បីផ្សាយដំណឹងល្អនៃព្រះបន្ទូលរបស់ព្រះអង្គ អោយបានច្រើនជាអតិបរមា។

ជន្លួញគោអាចយកមកប្រើសម្រាប់តម្កើងព្រះជាម្ចាស់បានដែរ បើមនុស្សដែលព្រះជាម្ចាស់ទ្រង់ប្រើ គឺជាមនុស្សដែលគាប់ព្រះហឫទ័យដល់ព្រះអង្គ។ សម័យលោកម៉ូសេ ព្រះជាម្ចាស់ប្រើដំបងរបស់លោកម៉ូសេ ដើម្បីសម្រេចការយ៉ាងធំ។ ព្រះអង្គប្រើគ្រាប់ដង្ហក់ ដើម្បីអោយស្ដេចដាវីឌអាចវាយប្រហារមកលើយក្សកូលីយ៉ាត់បាន។ ព្រះអង្គប្រើនាងដូកាដោយអោយនាងប្រើតែម្ជុល ហើយចេសតែប៉ុណ្ណោះ។ មានកុមារម្នាក់មាននំប៉័ង៥ដុំ ហើយនិងកូនត្រីតូច១២ ព្រះជាម្ចាស់អាចប្រើកុមារនេះបានដែរ។

អ្វីៗដែលយើងមាន បើចិត្តយើងស្មោះត្រង់ជាមួយនឹងព្រះ ព្រះអង្គអាចប្រើបានហើយ។ លោកអ្នកបងប្អូនអើយ តើលោកអ្នកមានអ្វីនៅនឹងដៃរបស់លោកអ្នកដែរឬទេ? បើលោកអ្នកពិតជាស្រឡាញ់ដល់ព្រះជាម្ចាស់ ព្រមទាំងអនុញ្ញាតអោយទ្រង់ប្រើលោកអ្នកបងប្អូន លោកអ្នកមិនចាំបាច់មានអ្វីច្រើនទេ។ បើមានលោកអ្នកមួយរូប មានវត្ថុជាប់ជាមួយនឹងលោកអ្នកមួយមុខទៀត បូកនិងព្រះជាម្ចាស់ ទាំង៣យ៉ាងនេះអាចសម្រេចការងារព្រះអង្គយ៉ាងច្រើនជាអតិបរមា បើលោកអ្នកព្រមអនុញ្ញាតអោយព្រះអង្គប្រើប្រាស់លោកអ្នក។

# ជំពូក ៤

*ឆាកចនា នាងដេបូរ៉ានិងលោកមេទ័ពបារ៉ាក*
*ការស្លាប់និងការបរាជ័យរបស់ស៊ីសេរ៉ា*

## នាងដេបូរ៉ានិងលោកមេទ័ពបារ៉ាក

១ លុះអេហ៊ុឌបានស្លាប់ទៅហើយ នោះពួកកូនចៅអ៊ីស្រាអែល គេ
ប្រព្រឹត្តសេចក្តីដែលលាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាម្តង
ទៀត
២ ទ្រង់ក៏លក់គេ ទៅក្នុងកណ្តាប់ដៃនៃយ៉ាប៊ីន ជាស្តេចស្រុក
កាណាន ដែលសោយរាជ្យនៅហាសោរ ស្តេចនោះមានមេទ័ព
ឈ្មោះស៊ីសេរ៉ា ដែលនៅហារ៉ូសែត-កូយីម
៣ ឯពួកកូនចៅ
អ៊ីស្រាអែល គេនាំគ្នាអំពាវនាវដល់ព្រះយេហូវ៉ា ពីព្រោះស្តេច
នោះមានរទេះដែក៩០០ ហើយក៏សង្កត់សង្កិនពួកកូនចៅអ៊ីស្រា
អែលជាខ្លាំង អស់រវាង២០ឆ្នាំ (ចៅហ្វាយ៤:១-៣)។

បន្ទាប់ពីលោកអេហ៊ុឌបានទទួលមរណកាល ជនជាតិសាសន៍អ៊ីស្រាអែលនាំគ្នាបែរត្រឡប់ទៅថ្វាយបង្គំរូបព្រះ រួចហើយធ្លាក់ខ្លួនចូលទៅក្រោមការសង្កត់សង្កិនជិះជាន់របស់សាសន៍ដទៃដូចមុនទៀត។ ព្រះជាម្ចាស់លក់សាសន៍អ៊ីស្រាអែលទៅអោយស្ដេចមួយអង្គឈ្មោះស្ដេចយ៉ាប៊ីន ដែលជាស្ដេចរបស់សាសន៍កាណាន។ ស្ដេចអង្គនេះមានមេទ័ពមួយរូបដ៏ខ្លាំងពូកែឈ្មោះស៊ីសេរ៉ា។ មេទ័ពស៊ីសេរ៉ាមានរទេះចម្បាំងធ្វើពីដែកចំនួន៩០០គ្រឿង។ រទេះចម្បាំងទាំងអម្បាលមាណនោះ ធ្វើអោយសាសន៍អ៊ីស្រាអែលងើបក្បាលមិនរួច ចេញពីការជិះជាន់របស់គេ ដោយព្រោះសាសន៍នេះមិនមានគ្រឿងសស្ត្រាវុធណាអាចទប់ទល់ជាមួយនឹងកម្លាំង របស់មេទ័ពស៊ីសេរ៉ាបានឡើយ។ ដោយសារមេទ័ពស៊ីសេរ៉ាប្រើរថក្រោះរបស់ខ្លួន គាបសង្កត់ដល់សាសន៍អ៊ីស្រាអែល បានជាស្ដេចយ៉ាប៊ីនអាចជិះជាន់សាសន៍អ៊ីស្រាអែលអស់រយៈពេល២០ឆ្នាំគត់។

**[4]រីឯនៅវេលានោះ មានស្ត្រី ជាហោរាម្នាក់ ឈ្មោះដេបូរ៉ា ជាប្រពន្ធឡាពិដូត នាងបានជំនុំជំរះរឿងរ៉ាវរបស់សាសន៍អ៊ីស្រាអែល [5]នាងតែងអង្គុយនៅក្រោមដើមលម៉ើដេបូរ៉ា ដែលនៅជាកណ្ដាលរ៉ាម៉ា នឹងបេត-អែល ក្នុងស្រុកភ្នំអេប្រាអិម ពួកកូនចៅអ៊ីស្រាអែលក៏ឡើងទៅឯនាងឱ្យបានជំនុំជំរះរឿងគេ (ចៅហ្វាយ ៤:៤-៥)។**

នៅពេលដែលសាសន៍អ៊ីស្រាអែលកំពុងទទួលការជិះជាន់ពីក្សត្រយ៉ាប៊ីន ដែលជាស្តេចនៃប្រទេសកាណាន មានស្ត្រីម្នាក់នាមដេបូរ៉ា ដែលគម្ពីរហៅថា លោកស្រីជាហោរាផង ជាពួកចៅហ្វាយផង។ លោកស្រីដេបូរ៉ាជាភរិយារបស់លោកឡាពិដូត។ លោកស្រីដេបូរ៉ាមានបុគ្គលិកលក្ខណៈជាស្ត្រីមួយរូប ដែលមានទឹកចិត្តអង់អាចក្លាហានណាស់។ ព្រះជាម្ចាស់តែងតាំងលោកស្រី អោយធ្វើជាពួកចៅហ្វាយរបស់សាសន៍អ៊ីស្រាអែល។ នៅពេលដែលនាងឡើងធ្វើជាចៅហ្វាយ ពួកមេទ័ពរបស់សាសន៍អ៊ីស្រាអែលភាគច្រើនខ្ជិលច្រអូសខ្លាំងណាស់។ នាងបានហៅពួកមេទ័ពទាំងនោះដើម្បីអោយបំពេញតួនាទីរបស់ខ្លួន។ ក្នុងចំណោមមេទ័ពទាំងអស់នោះ មានលោកមេទ័ពបារ៉ាកដែលជាមនុស្សខ្ជិលច្រអូលណាស់ដែរ។ លោកមេទ័ពបារ៉ាកត្រូវបំពេញតួនាទីរបស់ខ្លួនដើម្បីរំដោះសាសន៍អ៊ីស្រាអែល ប៉ុន្តែលោកមិនបានបំពេញតួនាទីរបស់លោកទេ។ លោកសុខចិត្តលាក់ខ្លួនពួនអាត្មា ក្រោមការជិះជាន់សង្កត់សង្កិនរបស់សាសន៍កាណានអស់រយៈពេល២០ឆ្នាំហើយ។

**៦ នាងចាត់គេឱ្យទៅហៅបារ៉ាកជាកូនអ័ប៊ីណោម ពីស្រុកកេដេស**
**-ណែបថាលីមក ហើយប្រាប់ថា ព្រះយេហូវ៉ា ជាព្រះនៃសាសន៍**
**អ៊ីស្រាអែល ទ្រង់បានបង្គាប់ថា ចូរនាំយកមនុស្ស១ម៉ឺននាក់ ពីពួក**
**កូនចៅណែបថាលី នឹងសាប់យូល៉ូន ចូលទៅឯភ្នំតាបោរទៅ**
**៧ នោះអញនឹងទាញនាំស៊ីសេរ៉ា ជាមេទ័ពរបស់ស្តេចយ៉ាប៊ីន ព្រម**

**ទាំងរទេះនឹងពួកពលទាំងប៉ុន្មានរបស់គេ មកឯឯង នៅត្រង់ស្ទឹងគីសុន ហើយនឹងប្រគល់គេមកក្នុងកណ្ដាប់ដៃនៃឯង ៨បារ៉ាកឆ្លើយតបថា បើលោកស្រីអញ្ជើញទៅជាមួយនឹងខ្ញុំផង នោះទើបខ្ញុំទៅ តែបើលោកមិនអញ្ជើញទៅជាមួយទេ នោះខ្ញុំក៏មិនទៅដែរ (ចៅហ្វាយ៤:៦-៨)។**

បើលោកអ្នកបងប្អូនមិនដែលស្គាល់មេទ័ពមានតែនាទី ប៉ុន្តែខ្ជិលច្រអូសមិនព្រមធ្វើការ លោកអ្នកមើលលោកមេទ័ពបារ៉ាកជាស្រាប់។ លោកមេទ័ពបារ៉ាកគួរតែបំពេញកិច្ចការរបស់ខ្លួន ធ្វើជាមនុស្សអង់អាចទប់ទល់ជាមួយនឹងសង្គ្រាម ដែលមេទ័ពសីសេរ៉ាប្រើរទេះចម្បាំង៩០០គ្រឿងសង្កត់សង្កិនដល់ជាតិសាសន៍របស់លោក។ ផ្ទុយទៅវិញ មេទ័ពដ៏អង់អាចនេះសម្ងំនៅក្រោមចង្កេះសំពត់របស់ស្ត្រីមួយរូប។ លោកមេទ័ពបារ៉ាក មិនព្រមចេញទៅធ្វើចម្បាំងទេ លើកលែងតែលោកស្រីដេបូរ៉ាយកសំពតគ្របក្បាលលោក។ លោកជឿថា បើហោរាដេបូរ៉ាអញ្ជើញទៅជាមួយ លោកនឹងអាចធ្វើសង្គ្រាមឈ្នះ។ លោកអ្នកបងប្អូនអើយ ព្រះជាម្ចាស់ប្រើស្ត្រីសម័យនោះ ក៏ដូចជានៅសម័យនេះដែរ។

**នាងឆ្លើយថា ដូច្នេះខ្ញុំនឹងទៅជាមួយនឹងអ្នកដែរ ប៉ុន្តែអ្នកនឹងគ្មានឈ្មោះដោយដំណើរដែលអ្នកទៅនោះទេ ដ្បិតព្រះយេហូវ៉ាទ្រង់**

**នឹងលក់សីសេរ៉ា ទៅក្នុងកណ្តាប់ដៃរបស់ស្ត្រីវិញ រួចដេបូរ៉ាក៏ក្រោកឡើង ទៅជាមួយនឹងបារ៉ាក ដល់កេដេស (ចៅហ្វាយ ៤:៩)។**

លោកស្រីដេបូរ៉ាព្រមទៅជាមួយនឹងមេទ័ពបារ៉ាក ប៉ុន្តែលោកស្រីបានជម្រាបលោកមេទ័ពបារ៉ាកជាមុនអោយហើយថា នៅពេលដែលព្រះជាម្ចាស់ប្រទានអោយឈ្នះសង្គ្រាមនោះ ឈ្មោះមេទ័ពបារ៉ាកមិនត្រូវលើកធ្វើជាវីរជនទេ។ អ្នកដែលត្រូវលើកជាវីរជនឈ្នះសង្គ្រាម គឺឈ្មោះលោកស្រីវិញ។ លោកមេទ័ពបារ៉ាកយល់ព្រមអំពីដំណើរនោះ។

## ការស្លាប់និងការបរាជ័យរបស់សីសេរ៉ា

នាងដេបូរ៉ាចេញទៅជាមួយនឹងមេទ័ពបារ៉ាក ដើម្បីធ្វើសង្គ្រាមរំដោះសាសន៍អ៊ីស្រាអែលជារាស្ត្ររបស់លោកស្រី អោយរួចអំពីការជិះជាន់របស់សាសន៍ដទៃ។ លោកមេទ័ពបារ៉ាកកេណ្ឌប្រមូលកងទ័ពរបស់លោក ដើម្បីចេញទៅធ្វើចម្បាំងជាមួយនឹងសត្រូវរបស់សាសន៍លោក។ ព្រះជាម្ចាស់បំបាក់ទ័ពរបស់មេទ័ពសីសេរ៉ា ដែលមានសុទ្ធតែរថក្រោះចំនួន៩០០គ្រឿង នៅពីមុខលោកស្រីដេបូរ៉ាទៅ។

**តែបារ៉ាកចេះតែដេញតាមរទេះ នឹងពួកពលគេទៅរហូតដល់ហារ៉ូសែត-កូយីម នោះពួកពលទាំងប៉ុន្មានរបស់ស៊ីសេរ៉ាក៏ស្លាប់ដោយមុខដាវអស់ គ្មានសល់ដល់ម្នាក់ឡើយ (ចៅហ្វាយ៤:១៦)។**

កងទ័ពសាសន៍អ៊ីស្រាអែលដែលដឹកនាំដោយលោកស្រីដេបូរ៉ា និងមេទ័ពបារ៉ាកបានដេញប្រហារកងទ័ពសាសន៍កាណានអោយអស់រលីងទៅ។

**រីឯស៊ីសេរ៉ា លោកបានរត់ទៅដល់ត្រសាលរបស់យ៉ាអែល ជាប្រពន្ធហេប៊ើរ សាសន៍កែននោះ ដ្បិតយ៉ាប៊ីន ជាស្តេចហាសោរ នឹងពួកគ្រួហេប៊ើរ ជាសាសន៍កែន បានមេត្រីនឹងគ្នា (ចៅហ្វាយ ៤:១៧)។**

នាងហេប៊ើរគឺជាសាសន៍ដទៃ ដែលរស់នៅក្នុងទឹកដីអ៊ីស្រាអែល ដែលទទួលការជិះជាន់ដោយសាសន៍កាណាន។

**១៨ យ៉ាអែលក៏ចេញមកទទួលស៊ីសេរ៉ា ដោយពាក្យថា អញ្ជើញចូលលោកម្ចាស់អើយ សូមអញ្ជើញចូលក្នុងផ្ទះខ្ញុំមក កុំខ្លាចអ្វីឡើយ លោកក៏ចូលទៅក្នុងត្រសាល ជាមួយនឹងនាង ហើយនាងយកភួយ**

> **មកគ្រប់ឱ្យ [១៩]លោកសូមដល់នាងថា សូមឱ្យទឹកមកខ្ញុំផឹកបន្តិចផង**
> **ដ្បិតខ្ញុំស្រេកណាស់ នោះនាងក៏បើកថង់ស្បែកដាក់ទឹកដោះឱ្យ**
> **លោកផឹក រួចគ្របលោកទៅវិញ [២០]លោកអង្វរដល់នាងថា សូម**
> **នាងឈរនៅមាត់ទ្វារត្រសាល បើមានអ្នកណាមកសួររកថា មាន**
> **អ្នកណានៅទីនេះឬទេ នោះសូមឆ្លើយថា គ្មានទេ រួចលោក**
> **ក៏ដេកលក់ស៊ប់ទៅ [២១]ឯយ៉ាអែល ជាប្រពន្ធហេប៊ើរ នាងក៏យក**
> **ចំរឹងត្រសាល១ នឹងញញួរកាន់នៅដៃ ដើរថ្នមៗ ចូលទៅឯលោក**
> **បោះចំរឹងនោះនៅត្រង់តើក ផ្ទុះទៅដល់ដីស្លាប់ទៅ (ចៅហ្វាយ**
> **៤:១៨-២១)។**

ពលទ័ពរបស់ស៊ីសេរ៉ា ត្រូវស្លាប់អស់ហើយ។ ពេលនេះមេទ័ពស៊ីសេរ៉ាមានបំណងតែម្យ៉ាង គឺចង់ពួនខ្លួន ដើម្បីអោយនៅសល់តែជីវិតតែប៉ុណ្ណោះ។ នាងយ៉ាអែលជាប្រពន្ធរបស់ហេប៊ើរ ជាសាសន៍កែណា។ នាងមិនមានចិត្តចង់ទុកជីវិតមេទ័ពស៊ីសេរ៉ាដែលជាអ្នកជិះជាន់ដល់សាសន៍អ៊ីស្រាអែលនោះឡើយ។ លោកមេទ័ពស៊ីសេរ៉ាជឿថា កាលណាលាក់ខ្លួននៅក្នុងផ្ទះនេះ នោះគាត់បានរួចជីវិតហើយ។ លុះលោកឃើញថា នាងយ៉ាអែលទទួលលោកដោយរាក់ទាក់ លោកក៏ជឿថាផ្ទះនេះមានការស្មោះត្រង់ជាមួយនឹងលោកទេ។ លោកក៏ដេកលក់ស៊ប់ទៅ។ កំពុងតែលោកដេកលក់យ៉ាងស៊ប់ នាងយ៉ាអែលបានយកចំរឹង ហើយនិងញញួរទៅបោះចំម្ញើករបស់លោក

មេទ័ពស៊ីសេរ៉ា រួចហើយមេទ័ពនេះក៏ស្លាប់ជីវិតបាត់ទៅ។ ក្រោយពីមេទ័ពស៊ីសេរ៉ាបានស្លាប់ទៅសាសន៍អ៊ីស្រាអែលបានរួចអំពីការជិះជាន់របស់សាសន៍ដទៃ។

យើងស្លេះការសិក្សាគម្ពីរចៅហ្វាយត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"